ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

ORIGINAL DOCUMENT/DOCUMENT ORIGINAL
(Date of receipt/Date de reception): 07 / APR / 2009
(Time/Heure): 14:00
Case File Officer/L'agent chargé du dossier:

អង្គជំនុំជម្រះសាលាដំបូង
Trial Chamber
Chambre de première instance

**<u>កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃដំណើរការនីតិវិធី-ករណី "ឌុច"</u>**

សំណុំរឿងលេខ ០០១/១៨-០៧-២០០៧-អវិតក/អ...

CERTIFIED COPY/COPIE CERTIFIÉE CONFORME
(Certified Date/Date de certification): 08 / APR / 2009
Case File Officer/L'agent chargé du dossier:

ថ្ងៃទី ០១ ខែមេសា ឆ្នាំ ២០០...

សវនាការលើអង្គសេចក្តី-ថ្ងៃទី ៣...

**សាធារណៈ**

រៀបចំដោយ: ឌុច ផារី និង Matteo CRIPPA

| <u>កំណត់ហេតុអ្នកចូលរួម</u> |
|---|
| ចំពោះមុខ ចៅក្រម និល ណុន (ប្រធាន), ចៅក្រម Silvia CARTWRIGHT, ចៅក្រម យ៉ា សុខន, ចៅក្រម Jean-Marc LAVERGNE, ចៅក្រម ធូ មណី |
| ចៅក្រមបម្រុង៖ ចៅក្រម យូរ ឧត្តរា (បម្រុង) និង ចៅក្រម Claudia FENZ (បម្រុង) |
| ក្រឡាបញ្ជី៖លោក លឹម ស៊ុយហុង,លោក ម៉ាតេអូ គ្រីប៉ា,លោកស្រី សែ គុលវុឌ្ឍី,កញ្ញា ណាតាសា លោក ឌុច ផារី |
| ការិយាល័យសហព្រះរាជអាជ្ញា៖ លោកស្រី ជាលាង, លោក រ៉ូបឺត ប៉ុទី, លោក យ៉េត ចរិយា, លោក វីលៀម ស្មីត, លោក តាន់សេណារុង, លោក សេង ប៊ុនឃាង,លោក ស្ទូអាត ហ្វត, លោក បូយ៉េន លីសាក,លោក ប៉ាក ចន្ទលីណូ |
| ជនជាប់ចោទ៖ កាំង ហ្គេកអ៊ាវ ហៅ ឌុច |
| មេធាវីជនជាប់ចោទ៖ លោក ការ សាវុត្ថ, លោក ហ្វ្រង់ស័រ រូស,លោកស្រី ហេឡិន យូណាក,លោក ចាន់ រ៉ាវុធ, កញ្ញា ហ្សង់ម៉ារី ត្រង់ទូល, កញ្ញា វីជីនី ឈេបផេនតៀ |



TRIAL CHAMBER CHAMBRE DE PREMIÈRE INSTANCE E.C.C.C. C.E.T.C.

| |
|---|
| ដើមបណ្ដឹងរដ្ឋប្បវេណី៖ [redacted] |
| មេធាវីដើមបណ្ដឹងរដ្ឋប្បវេណី៖លោក គង់ ពិសី,លោក យុង ផានិត , កញ្ញា ស៊ិលខេ ស្ទូហ្សិនស្គី , កញ្ញា ម៉ុច សុវណ្ណារី,លោកស្រី ម៉ាទីន ហ្សាកកាំង, លោកស្រី អានីដឺឡាហេ, កញ្ញា ទី ស្រ៊ីនណា, លោក អាឡាំង វើនើ, លោក ព្យែរ អូលីវៀស្ស |
| មន្ត្រីតុលាការ/ផ្នែកគ្រប់គ្រងតុលាការ៖ លោក សាន រ៉ាដា |

| **<u>ពេលវេលាទូទៅរបស់តុលាការ៖</u>** | | |
|---|---|---|
| ថ្ងៃ ទី ០១ ខែមេសា ឆ្នាំ ២០០៩ ព្រឹក | ចាប់ផ្ដើមម៉ោង៖ ៩.១០ | បញ្ចប់ម៉ោង៖ **១៦.១៥** |
| សម្រាកព្រឹក | ចាប់ផ្ដើមម៉ោង៖ ៩.៥០ | បញ្ចប់ម៉ោង៖១០.៣៥ |
| សម្រាក **អាហារថ្ងៃត្រង់** | ចាប់ផ្ដើមម៉ោង៖១២.០៥ | បញ្ចប់ម៉ោង៖១.៥០ |
| ពេលល្ងាច | ចាប់ផ្ដើមម៉ោង៖១.៥០ | បញ្ចប់ម៉ោង៖ ៣.២៧ |
| សម្រាកល្ងាច | ចាប់ផ្ដើមម៉ោង៖៣.២៧ | បញ្ចប់ម៉ោង៖៣.៣៤ |
| | ចំនួនម៉ោងសរុបរបស់តុលាការ៖ | **៤ម៉ោង ១៥ នាទី** |

| **<u>កិច្ចដំណើរការនីតិវិធីផ្សេងទៀត</u>** | | | |
|---|---|---|---|
| ប្រភេទបញ្ហា | លើកឡើងដោយ | ម៉ោងចាប់ផ្ដើម | ម៉ោងបញ្ចប់ |
| សំណើរបស់ភាគី និង ការព្រមព្រៀងលើអង្គហេតុ | មេធាវីដំណាងដើមបណ្ដឹងរដ្ឋប្បវេណី មេធាវីការពារក្ដី និង សហព្រះរាជអាជ្ញា | ៩.១០ | ១០.៣៥ |
| ការឆ្លើយតបទៅនិងសេចក្ដីសន្និដ្ឋានចោទរបស់សហព្រះរាជអាជ្ញា និងការបញ្ជាក់ | មេធាវីការពារក្ដី | ១០.៣៥ | ១០.៤០ |
| ការស្នើសុំឲ្យដោះលែងជនជាប់ចោទ | មេធាវីការពារក្ដី | ១០.៤០ | ១៤.០៥ |

| | | | |
|---|---|---|---|
| ការអានឆ្នូវការព្រមព្រៀងលើអង្គហេតុ | សហព្រះរាជអាជ្ញា និង មេធាវីការពារក្តី | ១៤.០៥ | ១៦.១៥ |

**សេចក្តីសង្ខេបនៃកិច្ចដំណើរការនីតិវិធីផ្សេងៗទៀត៖**

- ប្រធានប្រកាសបន្តសវនាការ ។

**សំណើរបស់ភាគី និងការព្រមព្រៀងលើអង្គហេតុ**

- អង្គជំនុំជម្រះឆ្លើយតបទៅនិងសំណើរបស់មេធាវីដំណាងដើមបណ្តឹងរដ្ឋប្បវេណីក្រុម២ ទាក់ទាងនិងការអានការព្រមព្រៀងលើអង្គហេតុក្នុងពេលសវនាការ ហើយចង្អុលបង្ហាញថា ឯកសាររបស់មេធាវីការពារក្តីនឹងត្រូវដាក់ក្នុងថ្ងៃនេះ ។ ប្រសិនបើមេធាវីការពារក្តីយល់ស្រប ខ្លឹមសារសង្ខេបនៃការព្រមព្រៀងនោះនឹងត្រូវអានក្នុងពេលសវនាការ ។

- អង្គជំនុំជម្រះណែនាំឱ្យមេធាវីដំណាងដើមបណ្តឹងរដ្ឋប្បវេណីឡើងនិយាយម្តងម្នាក់តាមលំដាប់នៃក្រុម ហើយសូមប្រាប់ឈ្មោះមុនពេលនិយាយ ។

- មេធាវីដំណាងដើមបណ្តឹងរដ្ឋប្បវេណីក្រុម ១ ៣ និង ៤ បានស្នើសុំឱ្យមានការបញ្ជាក់នូវការកំណត់កម្មវិធីសវនាការ និង បញ្ជីអង្គហេតុមួយចំនួនដែលបានលើកឡើងដោយអង្គជំនុំជម្រះ ។ មេធាវីបានបញ្ជាក់ថា ដើមបណ្តឹងរដ្ឋប្បវេណីភាគច្រើនដែលនឹងមកធ្វើសេចក្តីថ្លែងការណ៍នៅចំពោះមុខអង្គជំនុំជម្រះមិនជាប់ទាក់ទងនិងអង្គហេតុណាមួយនោះទេ ហើយ ក្នុងគោលបំណងដើម្បីរៀបចំឱ្យបានល្អ បានស្នើសុំការបញ្ជាក់ពីអង្គជំនុំជម្រះចំពោះការកំណត់កាលបរិច្ឆេទដើម្បីស្តាប់ចម្លើយពួកគាត់ ។

- មេធាវីដំណាងដើមបណ្តឹងរដ្ឋប្បវេណីក្រុម ២ បានលើកឡើងថា ចំពោះសេចក្តីសន្និដ្ឋានចោទរបស់សហព្រះរាជអាជ្ញា និងចម្លើយតបរបស់ជនជាប់ចោទនិងមេធាវីរបស់គាត់នោះ មេធាវីដំណាងដើមបណ្តឹងរដ្ឋប្បវេណីគួរតែត្រូវបានអនុញ្ញាតិដើម្បីឆ្លើយតបទៅនិង សេចក្តីសន្និដ្ឋាននេះ ។ មេធាវីបានលើកឡើងថា សំណើនេះគឺជាសំណើមួយដែលមានការកែប្រែពីសំណើរដែលបានដាក់ពីមុន ដែលស្នើសុំឱ្យមេធាវីតំណាងរដ្ឋប្បវេណីបានធ្វើសេចក្តីសន្និដ្ឋានបើក ។

- មេធាវីការពារក្តីបានលើកឡើងថា ឯកសារដែលមានការព្រមព្រៀងលើអង្គហេតុបានដាក់ជូន

មកតុលាការរួចហើយ ហើយអាចផ្សព្វផ្សាយដល់សាធារណៈជនបាន ។ មេធាវីក៏បានលើកឡើងផងដែរថា ប្រសិនបើអង្គជំនុំជម្រះមានបំណងចង់ផ្សព្វផ្សាយដល់សាធារណៈជន ឯកសារទាំងមូលគួរតែត្រូវអានក្នុងពេលសវនាការ ។ សហព្រះរាជអាជ្ញាក៏បានឯកភាពចំពោះការលើកឡើងនេះ ។ មេធាវីដំណាងដើមបណ្តឹងរដ្ឋប្បវេណីក្រុម ២ និង ៤ បានសុំឱ្យដាក់បញ្ចូលឯកសារទាំងនេះចូលទៅក្នុងសំណុំរឿង ចំណែកមេធាវីដំណាងក្រុម ៣ បានសុំឱ្យអាននូវអង្គហេតុដែលមានការព្រមព្រៀងនេះក្នុងពេលសវនាការ ។

- ក្រោយពីការពិភាក្សា អង្គជំនុំជម្រះសាលាដំបូងបានបង្គាប់ឱ្យសហព្រះរាជអាជ្ញាអាននូវអង្គហេតុដែលមានការព្រមព្រៀង និងអង្គហេតុដែលមិនមានការតវ៉ា ។

ការឆ្លើយតបទៅនិងការធ្វើសេចក្តីសន្និដ្ឋានចោទរបស់សហព្រះរាជអាជ្ញា/ការបញ្ជាក់

- មេធាវីការពារក្តីបានលើកឡើងថា អំណះអំណាងដែលបានលើកឡើងក្នុងអម្លុងពេលនៃការឆ្លើយតបទៅនិងសេចក្តីសន្និដ្ឋានចោទរបស់សហព្រះរាជអាជ្ញា គឺត្រូវបានធ្វើឡើងដោយមិនមានបំណងដើម្បីលើកពីយុត្តាធិការរបស់ អ.វ.ត.ក នោះទេ ប៉ុន្តែគ្រាន់តែចង់ឱ្យអង្គជំនុំជម្រះពិចារណាតែប៉ុណ្ណោះ ។

ការស្នើសុំឱ្យដោះលែងជនជាប់ចោទ

- មេធាវីការពារក្តីបានស្នើសុំឱ្យអង្គជំនុំជម្រះសាលាដំបូងដោះលែងជនចាប់ចោទបាននៅក្រៅឃុំ។ មេធាវីបានលើកឡើងថា ជនជាប់ចោទត្រូវបានចាប់ខ្លួននៅថ្ងៃទី ១០ ខែ ឧសភា ឆ្នាំ ១៩៩៩ ដោយអាជ្ញាធរនៃព្រះរាជាណាចក្រកម្ពុជា ហើយក្រោមកត្រូវបានបញ្ជូនទៅឱ្យតុលាការយោធា។ ជនជាប់ចោទត្រូវបានឃុំខ្លួនដោយតុលាការយោធា រហូតដល់ខែ កក្កដា ឆ្នាំ ២០០៧ ក្រោយមកគាត់ត្រូវបានសហចៅក្រមស៊ើបអង្កេតនៃអ.វ.ត.ក ចេញដីកាចាប់ខ្លួន និងបញ្ជូនមក អ.វ.ត.ក ។ មេធាវីការពារក្តីបានលើកឡើងថា ជនជាប់ចោទគួរតែត្រូវបានដោះលែង ដោយមូលហេតុថាតាមច្បាប់ជាតិ ក៏ដូចជាច្បាប់អន្តរជាតិ ជនជាប់ចោទមិនត្រូវបានឃុំខ្លួនយូរដូច្នេះនោះទេ ។ មេធាវីការពារក្តីបានបន្តថា តាមច្បាប់កម្ពុជា ការឃុំខ្លួនបណ្តោះអាសន្នមិនត្រូវលើកពី ៣ ឆ្នាំនោះទេ ហើយពេលវេលាដែលមានចែងក្នុងច្បាប់នោះបានផុតកំណត់ហើយ ។

- មេធាវីការពារក្តីបានលើកពីសេចក្តីសម្រេចរបស់ចៅក្រមស៊ើបអង្កេតរបស់តុលាការយោធា

ចុះថ្ងៃទី ២១ ខែ កក្កដា ឆ្នាំ ២០០៨ ហើយលើកឡើងថា តុលាការយោធាមិនមានសមត្ថកិច្ចលើជនជាប់ចោទទេ ដោយបទល្មើសដែលចោទនោះជាសមត្ថកិច្ចរបស់ អ.វ.ត.ក ហើយដូច្នេះហើយរឿងក្តីនេះត្រូវបានបញ្ជូនមក អ.វ.ត.ក ជាផ្លូវការ ។ មេធាវីការពារក្តីក៏បានយោងទៅលើរឿងក្តី Barayagwiza នៅតុលាការ ICTR និងសេចក្តីសម្រេចចុះថ្ងៃទី ០៣ ខែ វិច្ឆិកា ឆ្នាំ ១៩៩៩ របស់អង្គបុរេជំនុំជម្រះដែលបង្គាប់ឲ្យដោះលែងជនជាប់ចោទ ។

- មេធាវីការពារក្តីបានបំភ្លឺថា ការស្នើសុំឲ្យដោះលែងជនជាប់ចោទគឺធ្វើឡើងក្នុងអម្លុងពេលសវនាការ ហើយគាត់គួរតែត្រូវបានដាក់ក្នុងផ្ទះមួយដែលមានសុវត្ថភាព ព្រមទាំងស្ថិតនៅក្រោមលក្ខខ័ណ្ឌផ្សេងៗទៀតដែលកំណត់ដោយអង្គជំនុំជម្រះ ។ ប្រសិនបើសំណើនេះត្រូវបានបដិសេធរយៈពេលដែលឃុំខ្លួនជនជាប់ចោទនៅតុលាការយោធាគួរត្រូវបានយកមកពិចារណា ហើយបន្ថែមលើនេះទៀត គាត់មានសិទ្ធិក្នុងការទទួលបាននូវការបន្ថយទោស ជាសំណងទៅនិងការរំលោភលើសិទ្ធិរបស់គាត់ ។

- សហព្រះរាជអាជ្ញាបានលើកឡើងថា ការលើកឡើងរបស់មេធាវីការពារក្តីមិនមែនជារឿងមួយថ្មីនោះទេ ហើយបញ្ហានេះត្រូវបានដោះស្រាយម្តងរួចមកហើយដោយសហចៅក្រមស៊ើបអង្កេត និង អង្គបុរេជំនុំជម្រះ ។ សហព្រះរាជអាជ្ញាបន្តថា ដោយសារតែលក្ខណៈពិសេសរបស់ អ.វ.ត.ក តុលាការនេះជាតុលាការមួយដែលឯករាជពីតុលាការយោធា ហើយមិនត្រូវបានចងភ្ជាប់ទៅនិងសេចក្តីសម្រេចពីមុនរបស់តុលាការនោះឡើយ ។ ការឃុំខ្លួនជនជាប់ចោទនៅតុលាការយោធាគឺមិនត្រូវបានស្នើឡើងដោយសហព្រះរាជអាជ្ញា ដូច្នេះហើយបញ្ហានេះមិនជាប់ទាក់ទងទៅនិង អ.វ.ត.ក ហើយមិនគួរត្រូវបានយកមកពិចារណានោះទេ ។ សហព្រះរាជអាជ្ញាបានបន្ថែមថា៖
    - មិនមាននូវការប្រែប្រួលនូវស្ថានភាពរបស់ជនជាប់ចោទ ចាប់តាំងពីថ្ងៃនៃការចេញសេចក្តីសម្រេចរបស់អង្គបុរេ ដែលសម្រេចបន្តឃុំខ្លួនជនជាប់ចោទនោះទេ ។
    - វាមាននូវហានិភ័យសម្រាប់ជនជាប់ចោទក្នុងការរត់គេច ហើយនិតិវិធីនឹងបន្តដោយអវត្តមានរបស់គាត់
    - ការដោះលែងទាក់ទងនិងបញ្ហាសុវត្ថភាពរបស់ជនជាប់ចោទខ្លួនឯងផងដែរ ពីព្រោះថាការដោះលែងគាត់អាចធ្វើឲ្យមានការសងសិកពីជនរងគ្រោះ ហើងនេះក៏អាចធ្វើឲ្យប៉ះពាល់ដល់សណ្តាប់ធ្នាប់សាធារណៈផងដែរ ។

- ទាក់ទងទៅនិងសេចក្តីសម្រេចរបស់ចៅក្រមស៊ើបអង្កេតរបស់តុលាការឃោធា សហព្រះរាជអាជ្ញាបាលលើកឡើងថា សេចក្តីសម្រេចនោះគឺគ្រាន់តែជាការលះបង់នូវសមត្ថកិច្ចរបស់តុលាការឃោធាខ្លួនឯងលើជនជាប់ចោទ ក្រោយពីការបង្កើត អ.វ.ត.ក នៅឆ្នាំ ២០០៦ ។ ដូច្នេះហើយសហព្រះរាជអាជ្ញាសូមឲ្យបន្តការឃុំខ្លួនជនជាប់ចោទ ហើយចំពោះសំណើក្នុងការបន្ថយទោសជាសមត្ថកិច្ចរបស់អង្គជំនុំជម្រះក្នុងការសម្រេច ។

- រាល់មេធាវីដំណាងដើមបណ្តឹងរដ្ឋប្បវេណីទាំងអស់បានស្នើសុំលើកឡើងនូវការសង្កេតរបស់ខ្លួនចំពោះការលើកឡើងរបស់មេធាវីការពារក្តី ។

- អង្គជំនុំជម្រះសាលាដំបូងបានលើកឡើងថា អង្គជំនុំជម្រះនឹងធ្វើការពិចារណាលើសំណើរបស់មេធាវីដំណាងដើមបណ្តឹងរដ្ឋប្បវេណី ទាក់ទងទៅនិងការដោះលែងជនជាប់ចោទ ហើយនឹងធ្វើការឆ្លើយតបនៅថ្ងៃ ច័ន្ទ ទី ០៦ ខែ មេសា ឆ្នាំ ២០០៩ ។

- មេធាវីការពារក្តីបានលើកឡើងថា ចំពោះការលើកឡើងរបស់មេធាវីដើមបណ្តឹងរដ្ឋប្បវេណីដែលសុំឲ្យអង្គជំនុំជម្រះធ្វើការកែប្រែវិធាន ៨២(២) និង (៣) វាជាសមត្ថកិច្ចរបស់កិច្ចប្រជុំពេញអង្គដែលជាអ្នកមានសិទ្ធិសម្រេចកែប្រែវិធាន ។ ចំពោះវិធានបច្ចុប្បន្នបានចែងថា មេធាវីដំណាងដើមបណ្តឹងរដ្ឋប្បវេណីមិនមានសិទ្ធិក្នុងការការលើកឡើងនូវទឡ្ហីករណ៍ណាមួយទាក់ទងនិងការឃុំខ្លួនរបស់ជនជាប់ចោទឡើយ ។

**ការអាននូវអង្គហេតុដែលមានការព្រមព្រៀង**

- សហព្រះរាជអាជ្ញាបានអាននូវឯកសារដែលមាននូវការព្រមព្រៀងលើអង្គហេតុ (E5/11/2) ហើយក៏បានចង្អុលបង្ហាញនូវអង្គហេតុនីមួយៗដែលមានការព្រមព្រៀង ឬមិនមានការតវ៉ាពីមេធាវីការពារក្តី ។ មេធាវីការពារក្តីក៏បានបញ្ជាក់នូវការព្រមព្រៀងលើចំណុចនីមួយៗដែលបានអានផងដែរ ។

00301448



<u>ដីកា/សេចក្តីសម្រេចផ្ទាល់មាត់៖</u>

- សម្រេចឱ្យសហព្រះរាជអាជ្ញា និងមេធាវីការពារក្តីអានទូវអង្គហេតុ ដែលមានការព្រមព្រៀង និង មិនមានការតវ៉ា ។
- បង្គាប់ឱ្យនាំជនជាប់ចោទទៅកាន់មន្ទីឃុំឃាំង និងនាំមកកាន់សាលសវនាការវិញនៅថ្ងៃទី ០៦ ខែ មេសា ឆ្នាំ ២០០៩ មុនម៉ោង ៩.០០ ព្រឹក។

<u>ដីកាសម្រាប់ការពន្យាពេលសវនាការ</u>

- អង្គជំនុំជម្រះសម្រេចផ្អាកសវនាការ និងបន្តនៅថ្ងៃច័ន្ទ ទី ០៦ ខែ មេសា ឆ្នាំ ២០០៩ នៅម៉ោង ៩.០០ ព្រឹក ។

ភ្នំពេញ ថ្ងៃទី ០១ ខែ មេសា ឆ្នាំ ២០០៩

ក្រឡាបញ្ជី ... [illegible]

ឌុច [illegible] Matteo CRIPPA